**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតអបអរសាទរ

## លទ្ធផលជោគជ័យដ៏ត្រចះត្រចង់ នៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរាជធានីភ្នំពេញ

*សូមគោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាទីគោរពដ៏ខ្ពង់ខ្ពស់*

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ យើងខ្ញុំសូមគោរពសម្តែងនូវការអបអរសាទរ និងកតញ្ញូកតវេទិតាធម៌ដ៏ជ្រាលជ្រៅចំពោះមគ្គុទ្ទេសភាពពោរពេញដោយគតិបណ្ឌិត និងបញ្ញាញាណឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាស៊ានប្តូរវេន** ដែលបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ប្រកបដោយជោគជ័យដ៏ធំធេង និងទទួលបានលទ្ធផលដ៏ល្អត្រចះត្រចង់ ជាប្រវត្តិសាស្ត្រ។

កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១០ ដល់ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២នេះ ចំខួបអនុស្សាវរីយ៍ ៥៥ឆ្នាំ នៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ «អាស៊ាន» ដែលក្នុងអំឡុងពេល ៥៥ឆ្នាំកន្លងទៅនេះ អាស៊ានបានរួមចំណែកយ៉ាងសំខាន់ដល់សុខសន្តិភាព ទំនើបកម្ម ភាពធន់ និងបរិយាបន្ន សម្រាប់ប្រទេសជាតិ និងប្រជាជននៅតំបន់នេះ។

ជោគជ័យនៃកិច្ចប្រជុំកំពូលអាស៊ានលើកនេះបានលើកស្ទួយកិត្យានុភាពរបស់កម្ពុជាឱ្យស្មើមុខ និងស្មើសិទ្ធិជាមួយប្រទេសទាំងអស់លើសកលលោក ហើយបានបង្ហាញឱ្យពិភពលោកដឹងច្បាស់ពីការពិតជាក់ស្តែងនៃសច្ចភាព វឌ្ឍនភាព និងវិបុលភាពរបស់កម្ពុជា ក្រោមម្លប់សុខសន្តិភាព តាមមាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ។

យើងខ្ញុំទាំងអស់គ្នាពិតជាមានមោទនភាពប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរយ៉ាងក្រៃលែងចំពោះជោគជ័យដ៏ឧត្តុង្គឧត្តមរបស់កម្ពុជានាពេលនេះ ដែលប្រសូត្រចេញពីស្នាដៃដ៏ឆ្នើមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ទន្ទឹមនោះ ក្នុងនាមមន្ត្រីរាជការនៃក្រុមការងារចុះមូលដ្ឋានខេត្តក្រចេះ យើងខ្ញុំទាំងអស់គ្នាសូមចូលរួមអបអរសាទរជាមួយប្រជាជនក្នុងខេត្តក្រចេះទាំងមូល ថ្លែងអំណរគុណនិងដឹងគុណជាអនេកប្បការ ចំពោះមិត្តភាពនិងកិច្ចសហប្រតិបត្តិការល្អរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានបន្តជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត ជាក់ស្តែងរដ្ឋាភិបាលចិនបានផ្តល់ប្រាក់កម្ចីសម្រាប់ការសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ និងផ្លូវតភ្ជាប់ក្នុងខេត្តក្រចេះ។

ជាមួយក្តីរំភើបរីករាយប្រកបដោយមោទនភាពដ៏ជ្រាលជ្រៅនាឱកាសនេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈសូមគោរពប្រសិទ្ធពរជ័យសិរីសួស្តីមហាប្រសើរជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

ធ្វើនៅភ្នំពេញ ថ្ងៃ អាទិត្យ ៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារខេត្តក្រចេះ**

ព្រុំ-សុខា